ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣៧១ អក
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌ
លេខ ៧០ "ផ.ក្រ"
ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង ៨៖៣០ នាទីព្រឹក ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាប្រធានក្រុមប្រឹក្សា

លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង នៃសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧១ អក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] ចាន់ណា ភេទប្រុស អាយុ ១៧ឆ្នាំ (កើតឆ្នាំ២០០៥) ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរបើកអាបុលដី ទីកន្លែងកំណើត និង ទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សុផល "រស់" ម្ដាយឈ្មោះ [redacted] ចន្ធី "រស់" នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី៤ថ្មី ជាអនីតិជន ទោសពីមុនគ្មាន (ក្នុងឃុំ) ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១០០១ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ។

ដោយមានលោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចវត្តត្នោត ភូមិអណ្ដូងទឹក ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៨ និង៣០ នាទី ស្ថិតនៅចំណុចវត្តត្នោត ភូមិអណ្តូងទឹក ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល មានករណី **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចាន់ណា **ភេទប្រុស អាយុ១៧ឆ្នាំ** នៅពេលកើតហេតុមានកម្លាំងជំនាញនៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន សហការណ៍ជាមួយស្នងការនគរបាលខេត្តកណ្តាលបានចុះទៅបង្រ្កាបភ្លាមៗ នៅពេលដែលជនជាប់ចោទកំពុងតែដោះដូរថ្នាំញៀន ហើយក៏បានឃាត់ខ្លួនដោយឆែកឆេររកឃើញថ្នាំញៀនចំនួន០១កញ្ចប់ ស្មើនឹង ៣,៤៧ ក្រាម ដែលទិញពីឈ្មោះ **ធី** ភេទប្រុស រស់នៅភូមិព្រៃចំការ ដើម្បីយកទៅលក់បន្ត ។ តាមកំណត់ហេតុធ្វើតេស្តទឹកនោមរបស់ឈ្មោះ [redacted] ចាន់ណា គឺមានផ្ទុកនូវសារធាតុញៀន (+) ។

-**បានឃើញ** របាយការណ៍លេខ ៣៥២ **រ.ប.ក** ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃក្រសួងមហាផ្ទៃ ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៩៨ ដកសស ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៥២២ ដកសព** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៥៤៥ ដកជស** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ចាន់ណា បានឆ្លើយថា៖ ខ្លួនទទួលយកការចោទប្រកាន់ ដោយនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ម៉ោងប្រហែល៦ល្ងាច ខ្លួនជិះម៉ូតូទៅទិញថ្នាំញៀនប្រភេទម៉ាទឹកកកនៅម្តុំភូមិព្រៃចំការ ឃុំលំហាន ស្រុកអង្គស្នួល ខេត្តកណ្តាល ចំនួន០១កញ្ចប់ តម្លៃ២០ម៉ឺនរៀល ពីមនុស្សប្រុសម្នាក់ឈ្មោះ **ធី** ដើម្បីយកមកលក់បន្តដោយវែចជាកញ្ចប់តូចៗ ។ ក្រោយពីទិញថ្នាំបានហើយខ្លួនជិះម៉ូតូត្រលប់មកដល់ ភូមិអណ្តូងទឹក ឃុំលំហាច មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ បានតេមករកទិញថ្នាំញៀន ក៏ណាត់ជួបគ្នានៅភូមិវត្តត្នោត ពេលទៅដល់មុខវត្ត ខ្លួនឈប់ម៉ូតូកំពុងវែកថ្នាំស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួន និងដកហូតថ្នាំញៀនតែម្តង ។ កន្លងមកខ្លួនធ្លាប់លក់ថ្នាំញៀនបាន ៤-៥ដងហើយ ។ សំណូមពរ សុំឲ្យតុលាការបន្ធូរបន្ថយទោស ។

-**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ជនជាប់ចោទបានឆ្លើយស្របគ្នាគ្រប់ដំណាក់កាលថាពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហើយអំពើរបស់ជនជាប់ចោទរូបនេះគឺធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសង្គម ហេតុនេះស្នើសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមមាត្រា ៤០ និង ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។៚



Scanned with CamScanner

-លោកស្រីមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ បានសន្និដ្ឋានថាៈ កូនក្ដីខ្លួនបានឆ្លើយសារភាព ហើយជាអនីតិជន មានកម្រិតវប្បធម៌ទាប សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្ដីខ្លួន តាមមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ ។

ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្ដាប់ការសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្ដុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៨ និង៣០ នាទី ស្ថិតនៅចំណុចវត្តត្នោត ភូមិអណ្ដូងទឹក ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្ដាល មានករណី **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **ចាន់ណា ភេទប្រុស អាយុ១៧ឆ្នាំ** នៅពេលកើតហេតុមានកម្លាំងជំនាញនៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន សហការណ៍ជាមួយស្នងការនគរបាលខេត្តកណ្ដាលបានចុះទៅបង្ក្រាបភ្លាមៗ នៅពេលដែលជនជាប់ចោទកំពុងតែដោះដូរថ្នាំញៀន ហើយក៏បានឃាត់ខ្លួនដោយឆែកឆេរឃើញថ្នាំញៀនចំនួន ០១កញ្ចប់ ស្មើនឹង ៣,៤៧ ក្រាម ដែលទិញពីឈ្មោះ **ធី** ភេទប្រុស រស់នៅភូមិព្រៃចំការ ដើម្បីយកទៅលក់បន្ត ។ តាមកំណត់ហេតុធ្វើតេស្តទឹកនោមរបស់ឈ្មោះ [redacted] **ចាន់ណា** គឺមានផ្ទុកនូវសារធាតុញៀន ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ចាន់ណា** បានឆ្លើយថា ខ្លួនទទួលយកការចោទប្រកាន់ដោយនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ម៉ោងប្រហែល៦ល្ងាច ខ្លួនជិះម៉ូតូទៅទិញថ្នាំញៀនប្រភេទម៉ាទឹកកកនៅម្ដុំភូមិព្រៃចំការ ឃុំលំហាន ស្រុកអង្គស្នួល ខេត្តកណ្ដាល ចំនួន០១កញ្ចប់ តម្លៃ២០ម៉ឺនរៀល ពីមនុស្សប្រុសម្នាក់ឈ្មោះ **ធី** ដើម្បីយកមកលក់បន្តដោយវ៉ែចជាកញ្ចប់តូចៗ ។ ក្រោយពីទិញថ្នាំបានហើយខ្លួនជិះម៉ូតូត្រលប់មកដល់ ភូមិអណ្ដូងទឹក ឃុំលំហាច មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះ បានតេមករកទិញថ្នាំញៀន ក៏ណាត់ជួបគ្នានៅភូមិវត្តត្នោត ពេលទៅដល់មុខវត្ត ខ្លួនឈប់ម៉ូតូកំពុងវ៉ែកថ្នាំស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួន និងដកហូតថ្នាំញៀនតែម្ដង ។ កន្លងមកខ្លួនធ្លាប់លក់ថ្នាំញៀនបាន ៤-៥ដងហើយ ។ ឃើញថា ជនជាប់ចោទរូបនេះបានឆ្លើយសារភាព គប្បីតុលាការពិចារណា ។

៣-តាមលិខិតលេខ ១២៩៧ ផ.ត.អ.ជ.ប.គ.ញ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា សំណាកជាគ្រឿងញៀនប្រភេទក្រាមថ្លាដែលដកហូតបានពីឈ្មោះ [redacted] ចាន់ណា គឺជាប្រភេទ **មេតំហ្វេតាមីន** ដែលមានកម្រិតភាពសុទ្ធ ៧៦.៣២% ។ ដូច្នេះតាមការគណនាភាពសុទ្ធរបស់មេតំហ្វេតាមីនដែលចាប់ដកហូតបានគឺ ៣,៣៧ក្រាម x ៧៦,៣២% = ២,៥៧ក្រាម គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។៥



Scanned with CamScanner

៤-តាមរបាយការណ៍លេខ ៣៥២ រ.ប.ក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ របស់មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន នៃក្រសួងមហាផ្ទៃ បានសន្និដ្ឋានថា ឈ្មោះ [redacted] ចាន់ណា ពិតជាបានប្រព្រឹត្តសកម្មភាពរក្សាទុកជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

៥-តាមចម្លើយសារភាពរបស់ជនជាប់ចោទ របាយការណ៍របស់សមត្ថកិច្ច និងឯកសារជាភស្តុតាងនានាក្នុងសំណុំរឿង ឃើញថា មានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងអង្គហេតុ ដែលអាចបញ្ជាក់បានថា នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ នៅចំណុចមុខវត្តត្នោត ភូមិអណ្តូងទឹក ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] ចាន់ណា ពិតជាបានទៅទិញថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកក) ចំនួន ០១កញ្ចប់ ទម្ងន់ ៣,៤៥ក្រាម ពីឈ្មោះ ធី ដើម្បីយកមកប្រើប្រាស់និងលក់បន្ត ហើយត្រូវបានសមត្ថកិច្ចក៏បានចុះបង្ក្រាបនៅពេលជនជាប់ចោទឈ្មោះ [redacted] ចាន់ណា កំពុងតែដោះដូរថ្នាំញៀន ប្រាកដមែន ។

៦-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចាន់ណា ភេទប្រុស អាយុ ១៧ឆ្នាំ ពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចមុខវត្តត្នោត ភូមិអណ្តូងទឹក ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧-ជនជាប់ចោទឈ្មោះ [redacted] ចាន់ណា មានអាយុទើបតែ ១៧ឆ្នាំ ស្ថិតក្នុងវ័យជាអនីតិជន គប្បីតុលាការពិចារណានិងសម្រេចផ្តន្ទាទោសដោយផ្អែកលើមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

៨-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ជនជាប់ចោទបានឆ្លើយស្របគ្នាគ្រប់ដំណាក់កាលថា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហើយអំពើរបស់ជនជាប់ចោទរូបនេះគឺធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសង្គម ហេតុនេះស្នើសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមមាត្រា ៤០ និង ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន គប្បីតុលាការពិចារណា ។

៩-លោកស្រីមេធាវី [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនបានឆ្លើយសារភាព ហើយជាអនីតិជន មានកម្រិតវប្បធម៌ទាប សំណូមពរសុំឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន តាមមាត្រា ១៦៤ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការពិចារណា ។

១០-វត្ថុចាប់យករួមមាន ៖ ថ្នាំញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ៣,៤៧ក្រាម គប្បីតុលាការសម្រេចរឹបអូសតាមច្បាប់ ។



Scanned with CamScanner

# ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោសឈ្មោះ [redacted] ចាន់ណា ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ១៨ (ដប់ប្រាំបី) ខែ **បទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខវត្តឆ្នោត ភូមិអណ្តូងទឹក ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៤០ មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ។

២-វត្ថុចាប់យករួមមាន ៖ ថ្នាំញៀនប្រភេទមេតំហ្វេតាមីនទម្ងន់ ៣,៤៧ក្រាម **ត្រូវរឹបអូស** ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ **ផល ចាន់ណា** និងប្រកាសជាសាធារណៈ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ ។

-បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សាជំនុំជម្រះ** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

| | |
|---|---|
| **បានឃើញ** | កណ្តាល,ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ |
| **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |